**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**

**អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល**

លេខ: ០៤៣៧/២១ អសរ

## សេចក្តីប្រកាសព័ត៌មាន

## ស្តីពីលទ្ធផលនៃសន្និសីទសារព័ត៌មាន ថ្ងៃទី១៩ ខែមករា ឆ្នាំ២០២១

ព្រឹកថ្ងៃទី១៩ ខែមករា ឆ្នាំ២០២១ អង្គភាពអ្នកនាំពាក្យរដ្ឋាភិបាលបានរៀបចំសន្និសីទសារព័ត៌មាន ស្តីពី **«វឌ្ឍនភាពមូលដ្ឋានឃុំ-សង្កាត់ និងទិសដៅការងារបន្តរបស់រដ្ឋបាលខេត្តត្បូងឃ្មុំ»** ដែលមានវាគ្មិនចូលរួមគឺ៖

- **ឯកឧត្តម ស៊ាក ឡេង ប្រធានក្រុមប្រឹក្សាខេត្តត្បូងឃ្មុំ**
- **លោក ខូន ម៉ុណ្ណាន អភិបាល នៃគណៈអភិបាលស្រុកអូររាំងឪ**
- **លោក ម៉ែន អ៊ិន មេឃុំកងជ័យ ស្រុកអូររាំងឪ**

ខ្លឹមសារនៃសន្និសីទសារព័ត៌មាន មានគោលបំណងបង្ហាញសាធារណជនឱ្យបានយល់ច្បាស់ពីយន្តការប្រជាធិបតេយ្យថ្នាក់ក្រោមជាតិជាប្រវត្តិសាស្ត្រកម្ពុជា និងផ្សព្វផ្សាយពីសមិទ្ធផល ដែលរដ្ឋបាលថ្នាក់មូលដ្ឋានខិតខំប្រឹងប្រែងបំពេញការងារសម្រេចបាន ក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានឃុំ-សង្កាត់។

## I. សេចក្តីផ្តើម

ខេត្តត្បូងឃ្មុំ លាតសន្ធឹងតាមបណ្តោយទន្លេមេគង្គ និងជាខេត្តជាប់ព្រំដែន មានព្រំប្រទល់៖

- ខាងលិចទល់នឹង ខេត្តកំពង់ចាម
- ខាងកើតទល់នឹង ខេត្តតៃនិញ និងខេត្តប៊ិញភឿក ប្រទេសវៀតណាម
- ខាងជើងទល់នឹង ខេត្តក្រចេះ
- ខាងត្បូងទល់នឹង ខេត្តព្រៃវែង និងខេត្តតៃនិញ ប្រទេសវៀតណាម។
- ផ្ទៃដីសរុប មានទំហំ ៥ ២៥០,៥២គ.ម$^2$
- មាន ក្រុង១ និងស្រុក៦ ឃុំ-សង្កាត់ ចំនួន ៦៤ និងភូមិ ចំនួន ៨៧៣ភូមិ។

- ប្រជាពលរដ្ឋសរុប ចំនួន ៨៦៤ ៣១៩នាក់ ស្រី ៤៣៩ ៥៤៤នាក់ គិតជាគ្រួសារស្មើនឹង ១៩៦ ០៦៥គ្រួសារ។

## II. វឌ្ឍនភាពការងារ

វឌ្ឍនភាពការងារដែលខេត្តសម្រេចបានរួមមាន៖

### ❖ ក្រុមប្រឹក្សាខេត្ត

- ក្នុងឆ្នាំ២០២០ ក្រុមប្រឹក្សាខេត្តបានចូលរួមក្នុងកម្មវិធីផ្សេងៗសរុបចំនួន ២៦លើក ថែមទាំងបានបើកកិច្ចប្រជុំរបស់ខ្លួន និងគណៈកម្មាធិការនានា ៣៩លើក ក្នុងនោះកិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សា ១២លើក គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ១លើក គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ ១២លើក និងកិច្ចប្រជុំគណៈកម្មាធិកាលទ្ធកម្ម ១៤លើក។
- ក្រុមប្រឹក្សាខេត្ត បានអនុម័តក្របខ័ណ្ឌអភិវឌ្ឍន៍ខេត្ត ផែនការអភិវឌ្ឍន៍៥ឆ្នាំ និងផែនការវិនិយោគបី ឆ្នាំរំកិល ដែលមានសំណើគម្រោងពីគ្រប់រដ្ឋបាលឃុំសង្កាត់ ក្រុងស្រុក ខេត្ត មន្ទីរអង្គភាពជុំវិញខេត្ត ហើយក្នុងនោះ គម្រោងវិនិយោគរបស់រដ្ឋបាលខេត្តក្បែងឃុំសម្រាប់អនុវត្តក្នុងឆ្នាំ២០២០ ដែលបានដកស្រង់ចេញពីកម្មវិធីវិនិយោគបីឆ្នាំរំកិល (២០២០-២០២២) សរុបចំនួន ១៣គម្រោង ។ គម្រោងមូលនិធិក្រុង-ស្រុក មានចំនួន ២២គម្រោង និងគម្រោងមូលនិធិឃុំ/សង្កាត់ឆ្នាំមានចំនួន ៨១គម្រោង ។
- ក្រុមប្រឹក្សាខេត្ត បានរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់តាមក្រុង-ស្រុក លើកទី៣ អាណត្តិទី៣ តាមបណ្តាក្រុង-ស្រុកទាំង៧ មានអ្នកចូលរួមសរុបចំនួន ១ ៦៥១ នាក់ ស្រី ៤៤៥នាក់។ ជាលទ្ធផល យើងទទួលបានសំណួរ សំណូមពរ សរុបចំនួន ១០៤ បកស្រាយបំភ្លឺ និងដោះស្រាយចំនួន ១០៣។
- អង្គភាពច្រកចេញចូលតែមួយខេត្ត បានខិតខំប្រឹងប្រែងក្នុងការផ្តល់សេវា ក្នុងនោះទទួលបានសេវាចំនួន ១៦ ៣២៦សេវា ដែលសរុបជាទឹកប្រាក់ចំនួនប្រមាណ ១ ៩៦៣ លានរៀល លើវិស័យជំនាញចំនួន១២ បន្ថែមលើសេវារដ្ឋបាលដែលផ្តល់ដោយរដ្ឋបាលខេត្ត។
- ធ្វើការផ្សព្វផ្សាយតាមរយៈគ្រប់មធ្យោបាយ និងគ្រប់រូបភាព នៅគ្រប់បណ្តាឃុំ-សង្កាត់ទាំង៦៤ និងភូមិចំនួន ៨៧៣ភូមិ ដើម្បីយុទ្ធនាការប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ ហើយបានទទួលថវិកាពីក្រសួងស្ថាប័នពាក់ព័ន្ធ សប្បុរសជន ក្រុមហ៊ុន និងអង្គការដៃគូនានា សរុបចំនួន ៧៦ ៥៥៧ ០០០រៀល និងប្រាក់ដុល្លា ៩ ៧១២ដុល្លា និងសម្ភារៈរួមមាន ម៉ាស់ចំនួន ២២២ ០០០ ម៉ាស់ ម៉ាស៊ីនបាញ់ថ្នាំសម្លាប់មេរោគ ចំនួន ៣៥គ្រឿង ទឹកថ្នាំសម្លាប់មេរោគ ៤ធុង អាល់កុល ៥៩កាន ដែលលាងដៃ ៧៧៦ដប សាប៊ូលាងដៃ ៦១

កេស ស្មើនឹង ១ ៥២១ដុំ និងខិតប័ណ្ណសម្រាប់ផ្សព្វផ្សាយចំនួន១ ០០០សន្លឹក និងមាន ថវិកាសម្រាប់ចូលរួមទិញវ៉ាក់សាំងការពារជំងឺកូវីដ-១៩ ជូនរាជរដ្ឋាភិបាលកម្ពុជា សរុប ចំនួន ២២១ ២៤០ ០០០រៀល និងចំនួន ១៤ ៤៩០ដុល្លារ។

❖ **ស្រុកអូររាំងឪ**

- សក្តានុពលរបស់ស្រុករួមមាន៖
  - ផ្នែកទីប្រជុំជនស្រុក៖ នៅទីប្រជុំជនស្រុកមានផ្សារ ០១កន្លែង មានទីតាំងជាប់ ផ្លូវជាតិលេខ១១ និងមានប្រជាពលរដ្ឋមកពីតំបន់នានា ដើម្បីប្រកបអាជីវកម្ម និងធ្វើការដោះដូរទំនិញ នៅទីនោះ មានរោងចក្រកាត់ដេរសម្លៀកបំពាក់ ដែល អាចបង្កើតការងារជូនប្រជាពលរដ្ឋក្នុងមូលដ្ឋាន មានសិប្បកម្ម អាជីវកម្មជាច្រើន ទៀត។ ក្នុងនោះដែរក៏មានរោងម៉ាស៊ីនកិនស្រូវខ្នាតធំកម្រិតស្តង់ដារ ដែលអាច កិនស្រូវនាំចេញក្រៅប្រទេសចំនួន ០៥ទីតាំង និងម៉ាស៊ីនកិនស្រូវធម្មតាជា ច្រើនកន្លែងផ្សេងទៀត។
  - ផ្នែកដំណាំចំការ៖ ក្នុងស្រុកអូររាំងឪ មានតំបន់ដីក្រហម ដែលអាចឱ្យប្រជា ពលរដ្ឋដាំដំណាំរួមមាន កៅស៊ូ តាដែន មៀន ក្រូចថ្លុង អំពិលទឹក ទៀប ទុរេន ខ្នុរ សាវម៉ាវ ចេកអំបូងពណ៌លឿង ចេកពងមាន់ ចេកណាំវ៉ា ស្វាយចន្ទី និងម្រេច ជាលក្ខណៈក្រុមហ៊ុន និងជាលក្ខណៈគ្រួសារ។
  - ផ្នែកដំណាំស្រូវ៖ ស្រុកមានផ្ទៃដីសម្រាប់ធ្វើស្រូវវស្សា និងស្រូវប្រាំងចំនួន ១៧,៣៥០ហិកតា ស្រូវវស្សាមានចំនួន ១៦,០០០ហិកតា និងស្រូវប្រាំងចំនួន ១,៣៥០ហិកតា ទទួលបានទិន្នផលពី ៤,០០០ ទៅ ៤,២០០គក្រ/ហិចតា ដែលអាចផ្គត់ផ្គង់ដល់ប្រជាពលរដ្ឋក្នុងស្រុក និងមួយចំនួនទៀតនាំចេញទៅ ក្រៅស្រុកផងដែរ។
  - ផ្នែកតំបន់បឹងធម្មជាតិ ៖ ស្រុកមានបឹងធំចំនួន ០១កន្លែង (បឹងក្រពិត) ជា អតីតឡូតិ៍នេសាទលេខ៩ ដែលមានផ្ទៃបឹងទំហំ ៣,២៤៣.៦ហិកតា និង តំបន់អភិរក្សមេត្រីពូជចំនួន ៩,៦ហិកតា លាតសន្ធឹងពីឃុំមៀន ដល់ឃុំព្រះធាតុ ដែលមានមច្ឆាជាតិគ្រប់ប្រភេទ អាចផ្គត់ផ្គង់ក្នុងតំបន់ និងចេញទៅតំបន់ផ្សេងៗ ទៀត។
- បានរៀបចំឱ្យមានកម្លាំងប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ និងក្រុមប្រជាការពារនៅគ្រប់ឃុំ ដោយបានបង្កើតជាប៉ុស្តិ៍ប្រចាំការនៅតាមគោលដៅសំខាន់ៗ ប្រទាក់ក្រឡាគ្នាពីឃុំមួយ ទៅឃុំមួយទៀតដែលជាគោលដៅ ងាយរងគ្រោះ និងចុះឆែកអាវុធជាតិផ្ទះដល់ផ្ទះ។

- បានអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រក្នុងអំឡុងពេលជម្ងឺកូវីដ-១៩ បានចំនួន៣២៤គ្រួសារ (ក្រ១ស្មើ១៥៤គ្រួសារ និង ក្រ២ ស្មើ ១៧០ គ្រួសារ), អនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ ចំនួន៣៤នាក់, កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីសម្រាលកូន ចំនួន១៦នាក់ និងកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនកុមារអាយុក្រោម ២ឆ្នាំ ចំនួន០៦នាក់។
- បានផ្តល់សម្ភារៈបង្គន់អនាម័យ ដល់ប្រជាពលរដ្ឋក្រីក្រចំនួន៥០គ្រួសារ ឧបត្ថម្ភស្ត្រីក្រីក្រទៅសម្រាលកូននៅមណ្ឌលសុខភាពបានចំនួន ៤៤គ្រួសារ មត្តេយ្យសិក្សាសហគមន៍កំពុងដំណើរការគាំទ្រពីឃុំ ចំនួន ៣ថ្នាក់។

## III. ទិសដៅការងារបន្ត

### ❖ ក្រុមប្រឹក្សាខេត្ត

- បន្តរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សាខេត្ត និងរៀបចំផែនការចុះគាំទ្រនៅមូលដ្ឋាន ដើម្បីប្រមូលតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋ ក្នុងការអនុវត្តនូវមុខងារជាជម្រើសរបស់ក្រុមប្រឹក្សា។
- បន្តការគាំទ្រក្នុងការអនុវត្តមុខងារ ដែលបានប្រគល់ដោយក្រសួងស្ថាប័ន ថ្នាក់ជាតិ។
- បន្តការរៀបចំ និងអនុម័តកម្មវិធីវិនិយោគបីឆ្នាំរំកិលឱ្យទាន់ពេលវេលា និងការរៀបចំផែនការថវិកាប្រចាំឆ្នាំ។
- ពង្រឹងការអនុវត្តតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាឱ្យស្របតាមលិខិតបទដ្ឋានគតិយុត្តិនានា និងបែងចែកភារកិច្ចចូលរួមគាំទ្រការងាររាល់ការចេញសេចក្តីសម្រេច របស់អង្គប្រជុំក្រុមប្រឹក្សា។

### ❖ ស្រុកអូររាំងឪ៖

- បន្តកសាង និងពង្រឹងសន្តិសុខ សុវត្ថិភាព ជូនប្រជាពលរដ្ឋនៅគ្រប់ទីកន្លែង និងគ្រប់ពេលវេលា តាមរយៈការខិតខំលុបបំបាត់បទល្មើសគ្រប់ប្រភេទក្នុងមូលដ្ឋានភូមិ ឃុំ ទូទាំងស្រុក។
- បំផុសឱ្យមានកិច្ចសហការចូលរួមជាមួយសមត្ថកិច្ច ពីគ្រប់សមាសភាពផ្សេងៗ ទាំងក្នុងវិស័យសាធារណៈ ទាំងវិស័យឯកជន អង្គការក្រៅរដ្ឋាភិបាល និងប្រជាពលរដ្ឋគ្រប់រូប ដើម្បីកសាងកម្លាំងសរុប ក្នុងការអនុវត្ត គោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព។
- ជំរុញការផ្សព្វផ្សាយ និងបណ្តុះបណ្តាលបច្ចេកទេសកសិកម្មបែបថ្មី ដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ។

- ការិយាល័យច្រកចេញចូលតែមួយ នៃរដ្ឋបាលស្រុកអូររាំងឪ បានផ្តល់សេវាជូនប្រជាពលរដ្ឋបានចំនួន ៨,៣៩៥នាក់ ( ស្រី ៤,៦៨៣នាក់ ) សរុបសេវាដែលបានផ្តល់ជូនបានចំនួន ៨,៥៥៤សេវា ដែលទទួលបានចំណូលសរុបចំនួន ១១,៧៥៧,០០០រៀល។
- រដ្ឋបាលឃុំទាំង៧ ក្នុងស្រុកអូររាំងឪ បានផ្តល់សេវាសំបុត្រអត្រានុកូលដ្ឋានជូនប្រជាពលរដ្ឋបានចំនួន ២,៨៥០នាក់( ស្រី ១,៦៩០នាក់ ) ក្នុងនោះសំបុត្របញ្ជាក់កំណើតបានចំនួន ៩៨១នាក់(ស្រី៤៩៥នាក់) សំបុត្រកំណើតសរុបចំនួន១,០១៩នាក់ (ស្រី ៥៤២នាក់ )សំបុត្រអាពាហ៍ពិពាហ៍សរុបចំនួន៤៦៥គូ និងសំបុត្រមរណភាពសរុបចំនួន៣៨៥នាក់ ( ស្រី ១៨៨នាក់ )។
- អធិការដ្ឋាននគរបាលស្រុក បានធ្វើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ជូនប្រជាពលរដ្ឋក្នុងស្រុក គិតចាប់ ពីថ្ងៃទី០១ មករា ឆ្នាំ២០២០ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ សរុបចំនួន ២,០៦០នាក់ (ស្រី ៩៨៨នាក់)។ ការធ្វើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ បច្ចុប្បន្នបានផ្ទេរពីអធិការដ្ឋាននគរបាលស្រុក មកនៅការិយាល័យច្រកចេញចូលតែមួយស្រុក ដោយមានមន្ត្រីនគរបាលជំនាញប្រចាំការចាំធ្វើជូនប្រជាពលរដ្ឋ ដោយមិនគិតថ្លៃ និងធ្វើជារៀងរាល់ថ្ងៃមិនគិតថ្ងៃឈប់សម្រាក សៅរ៍ អាទិត្យ ឬថ្ងៃបុណ្យជាតិឡើយ។

❖ **ឃុំគងជ័យ**

- ការងារអភិវឌ្ឍន៍៖
    - គម្រោងអភិវឌ្ឍន៍ប្រើប្រាស់ថវិកាមូលនិធិឃុំ៖ បានសាងសង់ផ្លូវបេតុងអាមេប្រវែង ២១៨ម៉ែត្រ ទទឹង ៥ម៉ែត្រ ទីតាំងភូមិលេខ១ ឃុំគងជ័យ ប្រើប្រាស់ថវិកាចំនួន ១៨២,៩៣៤,០០០រៀល ( មូលនិធិអភិវឌ្ឍន៍ឆ្នាំ២០១៨ ), ស្តារប្រឡាយដី១ខ្សែប្រវែង ៤,២០០ ម៉ែត្រ និងលូ ៣កន្លែង ទីតាំងភូមិអូដក់ក្រាយ ភូមិព្រំខេត្ត ភូមិស្ទឹងរាង ភូមិថ្មល់កែង និងភូមិស្ទឹងជ័យប្រើប្រាស់ថវិកាចំនួន ១១៦,៧៥០,០០០រៀល ( មូលនិធិអភិវឌ្ឍន៍ឆ្នាំ ២០១៩ ), សាងសង់ផ្លូវបេតុងអាមេប្រវែង ១,០៧៨ម៉ែត្រ ទទឹង ៥ម៉ែត្រ និងលូ ៥កន្លែង ទីតាំងភូមិគងជ័យ ប្រើប្រាស់ថវិកាចំនួន ២២៤,១៤០,០០០រៀល ( មូលនិធិអភិវឌ្ឍន៍ឆ្នាំ២០២០ )។
- ការអនុវត្តគោលនយោបាយភូមិឃុំ មានសុវត្ថិភាព រដ្ឋាភិបាលឃុំ បានផ្សព្វផ្សាយឱ្យប្រជាពលរដ្ឋ ដើម្បីការពារសុវត្ថិភាពភូមិដ្ឋានរបស់យើងគ្រប់ៗគ្នា ក្នុងនោះបានពង្រឹងកម្លាំងប្រជាការពារ ចំនួន ២២០នាក់ ស្រី ០នាក់ មានគោលដៅប្រចាំការពេលយប់ ដោយបានសហការជាមួយកម្លាំងនគរបាលប៉ុស្តិ៍រដ្ឋបាលឃុំគងជ័យជាប្រចាំ។

- រៀបចំវេទិកាពិគ្រោះយោបល់ជាសាធារណៈជាមួយប្រជាពលរដ្ឋ ស្វែងយល់ពីសុខទុក្ខ និងតម្រូវការនៅមូលដ្ឋាន ដើម្បីរៀបចំផែនការឆ្លើយតប។
- បង្កើនការអប់រំ និងលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋលើការទុកដាក់ ការគ្រប់គ្រងសំរាម សំណល់រឹង រាវ ព្រមទាំងត្រៀមរៀបចំទីលាន និងបច្ចេកទេសក្នុងទុកដាក់ និងកែច្នៃសំរាម។

❖ **ឃុំគងជ័យ៖**

- បន្តការយកចិត្តទុកដាក់បម្រើសេវារដ្ឋបាលជូនប្រជាពលរដ្ឋអោយលឿន រហ័ស និងមិនរើសអើង។
- បន្តការខិតខំពង្រឹងការអនុវត្តគោលនយោបាយ ភូមិឃុំមានសុវត្ថិភាពពង្រឹងក្រុមប្រជាការពារជាប្រចាំ។
- ផ្សព្វផ្សាយចំណេះដឹងផ្នែកច្បាប់ ជូនប្រជាពលរដ្ឋ, រៀបសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិល, អនុវត្តគម្រោងមូលនិធិប្រចាំឆ្នាំ និងចុះពង្រឹងការរៀបចំសណ្តាប់ធ្នាប់ក្នុងមូលដ្ឋាន។
- បន្តការផ្សព្វផ្សាយពីវិធានការការពារការទប់ស្កាត់ ជំងឺឆ្លង។
- បន្តការផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ ឱ្យយល់ដឹងពីការរស់នៅស្អាតហូបស្អាតនិងធ្វើអនាម័យបរិស្ថាន។
- ខិតខំគៀងគរដៃគូរ អ្នកវិនិយោគ និងសប្បុរសជនដើម្បីចូលរួមអភិវឌ្ឍន៍នៅក្នុងមូលដ្ឋាន។

ថ្ងៃអង្គារ ៦កើត ខែមាឃ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែមករា ឆ្នាំ២០២១